# ល្ខោននិយាយ

ព្រះរាជាណាចក្រកម្ពុជា មានទម្រង់ល្ខោនសម្បូណ៌បែប ដូចជាល្ខោនព្រះរាជទ្រព្យ ឬល្ខោនក្បាច់បុរាណខ្មែរ ល្ខោនខោល ល្ខោនស្បែក ល្ខោនមហោរី ល្ខោនភ្លេងការ ល្ខោនគែន ល្ខោនពោលស្រី ល្ខោនប្រាមោជ្ជទ័យ ល្ខោនអាប៉េ ល្ខោនយីកេ ល្ខោនបាសាក់ និងល្ខោននិយាយ។ល។ ទម្រង់ល្ខោនដែលបានរៀបរាប់ខាងលើនេះ មានអាយុកាលវែងនិងយូរលង់ណាស់មកហើយ ដែលដូនតានិងសិល្បករសិល្បការិនីខ្មែរបានថែរក្សា ទោះបីមួយចំនួនតូច ក៏បានបាត់បង់និងកំពុងស្តារឡើងវិញនៅកម្ពុជាក៏ដោយ។

ដោយយកការនិយាយ ពាក្យពេចន៍ ការប្រើពាក្យសម្តី និងវោហាសាសន៍ជាធំ ខ្មែរយើងហៅទម្រង់ល្ខោននេះថា "ល្ខោននិយាយ"។ ដោយឡែកល្ខោននិយាយកម្ពុជាមានប្រភពកើតឡើងនៅក្នុងអំឡុងទសវត្ស ១៩៤០ (១៩៤៩) ឧទ្ទេសនាមដោយសាស្ត្រាចារ្យបារាំងដែលបង្រៀនអក្សរសិល្ប៍បារាំងនៅវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញ ជាពិសេសគឺលោក ហ្គី ប៉ូរ៉េ (Gui Porée) ដែលបាននាំសិស្សសម្តែងអន្ទើនានានៃរឿងផ្សេងៗ ដែលគាត់បង្រៀននិងនាំសិស្សតម្លើងរឿងខ្លីៗ (Scènette) ដែលមានពាក្យពេចន៍ឆ្លងឆ្លើយគ្នាគួរឱ្យចាប់អារម្មណ៍ ហើយរឿងទាំងនោះ ក៏ត្រូវបានជ្រើសរើសយកទៅសម្តែងនៅក្នុងពិធីបញ្ចប់ឆ្នាំសិក្សានីមួយៗផង។[1]

យើងគួរបញ្ជាក់ផងដែរថា គឺនៅជំនាន់នោះហើយដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជូននិស្សិតខ្មែរឱ្យទៅសិក្សាមុខវិជ្ជាល្ខោននៅប្រទេសបារាំង។ លោក ពេជ្រ ទុំក្រវិល បានអះអាងថា ប្រមាណឆ្នាំ១៩៥៦ ក្រសួងសិក្សាធិការជាតិក៏បានប្រមូលគរុសិស្សនៅវិទ្យាស្ថានជាតិគរុកោសល្យមួយចំនួនឱ្យហាត់ល្ខោននិយាយនេះ ជាផ្លូវការ។ ទើបមកដល់អំឡុងឆ្នាំ១៩៥៩ ទើបក្រសួងសិក្សាធិការជាតិ បើកសាលាជាតិផ្នែកល្ខោន (សាលាល្ខោនជាតិ) ដែលមានទីតាំងដំបូងនៅម្តុំវត្តភ្នំ។[2] បន្ទាប់ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានបង្កើតឡើងនៅឆ្នាំ១៩៦៥ សាលាជាតិផ្នែកល្ខោនក៏បានទៅនៅ

---

[1] ពេជ្រ ២០០៣: ២៣០

[2] ពេជ្រ ២០០៣: ២៣០

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ក្រោមមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ (ផ្នែកល្ខោននិយាយ)។[៣] ល្ខោននិយាយនៅពេលនោះ មានការគាំទ្រពីទស្សនិកជននិងមហាជនជាច្រើននិងមានកម្មវិធីសម្តែងលើឆាកនិងតាមវិទ្យុជាតិ និងទូរទស្សន៍ជាតិ ប្រកបដោយភាពរីកចម្រើនខ្លាំងក្លាគួរឲ្យកត់សម្គាល់។ នៅពេលនោះដែរ កម្ពុជាក៏មានអ្នកនិពន្ធនិងដឹកនាំរឿងល្ខោនដ៏ចំណានៗដូចជា៖ លោក ហង់ ធុនហាក់ លោក ពៅ យូឡេង លោក អ៊ុំ ឈីន លោក មាស គក លោក ឆេង ផុន លោក ហង់ ដួន លោក នួន កន លោក សុខ សៅវណ្ណគុណ លោក លី គឹមអួង លោក ហួត គឹមលាង លោក ហ៊ីង ប៊ុនថុន លោក ប៉ុល សំអឿន លោក ផឹក សំផេន និងអ្នកស្រី អ៊ូ ចាន់ថនជាដើម។ ក្រោមកិច្ចដឹកនាំនិងបណ្តុះបណ្តាលរបស់គ្រូជំនាញដ៏ល្អៗទាំងនេះ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមានការរីកចម្រើន ដោយបានបណ្តុះបណ្តាលអ្នកនិពន្ធរឿងល្ខោនជាច្រើននាក់។ នៅពេលនោះ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានរៀបចំជាកម្មវិធីសម្តែងជូនសិស្សានុសិស្សនិងសាធារណៈជនទូទៅនៅតាមខេត្ត ក្រុង និងជនបទទូទាំងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ។

សាស្ត្រាចារ្យនិងសិល្បករសិល្បការិនីខ្មែរជំនាន់នោះ បាននិពន្ធនិងតម្លើងរឿងជាច្រើនមានដូចជារឿង៖ ពុទ្ធប្រវត្តិ ព្រះវេស្សន្តរ សុវណ្ណសាម សព្វសិទ្ធ ពុទ្ធិសែននាងកង្រី ព្រះគោព្រះកែវ សោភ័ណរាត្រី កូនអ្នកណា? កុលាបប៉ៃលិន ចិញ្ចៀនបញ្ចាំចិត្ត ផ្កាស្រពោន ថ្មរាំ ល្បិចស្នេហាស្រុកស្រែ វង្សត្រកូលកំសត់ ចៅកែចិត្តចោរ ដើមធ្លករក្សាជាតិ លោហិតតែមួយ ប្រាង្គសិលាកញ្ញាអង្គរ ស្ទឹងកំចាយមារ និងរៀមច្បងយើងជាដើម។ មិនត្រឹមតែរឿងខ្មែរប៉ុណ្ណោះទេ សិល្បករនិងសិល្បការិនីផ្នែកល្ខោននិយាយរបស់យើងក៏បានតម្លើងរឿងបរទេស មានស្នាដៃរបស់អ្នកនិពន្ធធំៗល្បីល្បាញក្នុងពិភពលោកដូចជា បាល័យទ័យា (Hamlet) សុបិននិមិ្មតនារវស្សន្តរដូវ និងរ៉ូម៉េអូ-ហ្សូលីយែត (Romeo-Juliet) ដោយលោកសេកស្ពៀរ (Shakespeare) ជនកំណាញ់ក្រៅតម្រា (L´Avare) និងហ្សូរ៉ែកដង់ដាំង ដោយលោក ម៉ូលីយ៉ែរ (Molière) ជាដើម។

[៣] មហាវិទ្យាល័យសិល្បៈនាដសាស្ត្រនាពេលនោះ មានបួនផ្នែក គឺផ្នែករបាំប្រពៃណី (គ្រប់គ្រងដោយ លោក ឆេង ផុន) ផ្នែកចម្រៀងជាពួក (គ្រប់គ្រងដោយ លោក លី គឹមអួង) ផ្នែករបាំបាល្លេបស្ចឹមប្រទេស (គ្រប់គ្រងដោយ អ្នកស្រី អ៊ូ ចាន់ថន) និងផ្នែកល្ខោននិយាយ (គ្រប់គ្រងដោយ លោក សុខ សៅវណ្ណគុណ)។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## *អត្ថបទ៖ ល្ខោននិយាយ*

*នាពេលបច្ចុប្បន្ននេះ ល្ខោននិយាយមិនសូវមានវត្តមាននិងសម្ដែងនៅក្នុងកម្មវិធីសាធារណៈដូចពីកាលសម័យមុនសង្គ្រាម និងខ្មែរក្រហមប្រល័យពូជសាសន៍ឡើយ។ ល្ខោននិយាយមាននៅតែក្នុងកម្មវិធីសិក្សា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនិងសាលាមធ្យមវិចិត្រសិល្បៈតែប៉ុណ្ណោះ។ យ៉ាងណាមិញនៅក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃនៃសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាពល់ទិវាវប្បធម៌ជាតិប្រចាំឆ្នាំ ៣មីនា ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" បានរៀបចំជាមហោស្រពសិល្បៈ ជាវេទិកាផ្ដល់ឱកាសជូនដល់យុវសិស្ស និងនិស្សិតទូទាំងប្រទេស គិតគូរ សិក្សា ស្រាវជ្រាវ តម្លើងស្នាដៃ និងចូលរួមសម្ដែងនៅក្នុងមហោស្រព។*

*នៅក្នុងន័យនេះ ក៏ដូចជាវាសនាអនាគតនៃទម្រង់សិល្បៈទស្សនីយភាពខ្មែរដទៃទៀតដែរ គឺវានឹងអន់ថយ បាត់បង់ ឬសាបសូន្យ ប្រសិនបើយើង ជាពិសេសយុវជនយុវនារីដែលជាអ្នកបន្តវេន មិនយកចិត្តទុកដាក់ ជ្រោមជ្រែង បណ្ដុះបណ្ដាល រៀនសូត្រ លើកស្ទួយ និងផ្សព្វផ្សាយបន្ត។*

## **ឯកសារយោង**

*ពេជ្រ ទុំក្រវិល*
*២០០៣. ទស្សនីយភាពខ្មែរ, ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*

# សកម្មភាពសំដែងល្ខោននិយាយ







អត្ថបទដោយ៖ បណ្ឌិត សំ សំអាង